**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

## សារលិខិតថ្វាយព្រះពរ

**សូមក្រាបបង្គំទូលថ្វាយ**

**សម្ដេចព្រះមហាក្សត្រ នរោត្តម សីហមុនី ព្រះវររាជមាតាជាតិខ្មែរ**

**ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល ក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ**

**សម្ដេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !**

ក្នុងឱកាសដ៏នក្ខត្តឫក្ស ប្រកបដោយសេចក្ដីសោមនស្សរីករាយ ក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមទូលព្រះបង្គំនិងភរិយា សូមព្រះបរមរាជានុញ្ញាតលំឱនកាយវាចាចិត្តក្រាបបង្គំទូលថ្វាយនូវព្រះរាជសព្ទសាធុការពរជ័យ បវរសួស្ដី សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់យ៉ាងថ្វាយ **សម្ដេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ** សូមទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលរឹងមាំ ព្រះជន្មាយុយឺនយូរ ដើម្បីភាពសុខដុមរមនាសម្បូរសប្បាយចម្រុងចម្រើនរុងរឿង។

ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតសម្ដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះមហាករុណាទិគុណរបស់ **សម្ដេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ** ដែលជានិច្ចកាលព្រះអង្គតែងបានលះបង់ព្រះកាយពល ដើម្បីបុព្វហេតុបម្រើជាតិមាតុភូមិ ក្នុងវិស័យព្រះពុទ្ធសាសនា សង្គមកិច្ច និងអប់រំសិក្សាធិការ សំដៅលើកកម្ពស់ជីវភាព និងសុខុមាលភាពជូនប្រជារាស្ត្រ។

ជាថ្មីម្ដងទៀត ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំឱនកាយវាចាចិត្តបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្ដិសិទ្ធិទាំងឡាយក្នុងលោក ម៉ានទេវតាឆ្នាំថ្មី ទេវតារក្សាព្រះមហាស្វេតច្ឆត្រ និងបារមីនៃអតីតព្រះមហាក្សត្រ មហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គសូមទ្រង់ព្រះមេត្តាប្រោះព្រំសព្ទសាធុការពរជ័យ បវរសួស្ដី សិរីមង្គល មហាប្រសើរថ្វាយ **សម្ដេចព្រះមហាក្សត្រព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈ សូមព្រះអង្គប្រកបដោយ ព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីទ្រង់គង់នៅជាម្លប់ដ៏ត្រជាក់ដល់ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ជាកូន **ចៅ ចៅទួត** របស់ព្រះអង្គជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្ដេចព្រះមហាក្សត្រ នរោត្តម សីហមុនី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈ ទ្រង់ព្រះមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្ដីគួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស។

ថ្ងៃអង្គារ ១១កើត ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញថ្ងៃទី១២ខែមេសាឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្ដេចពិជ័យសេនា **ទៀ បាញ់**